ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ១០ លេខ ៦

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC

កសវ



Work Activities

ប្រចាំខែមិថុនា ឆ្នាំ២០១៧



# មាតិកា


| ល.រ | បរិយាយ | លេខទំព័រ |
|---|---|---|
| I- | កិច្ចប្រជុំជំនាញបច្ចេកទេស | |
| | ១- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត | ១ |
| | ២- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបង្កើតវិទ្យាស្ថានជាតិអប់រំពិសេស | ២-៣ |
| II- | សកម្មភាពការងាររបស់ក្រុមវាយតម្លៃលើផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត ( ក្រុម RIA ) | |
| | - ប្រជុំបូកសរុបប្រចាំត្រីមាសទី១ ឆ្នាំ២០១៧ ស្តីពីការអនុវត្តកម្មវិធីវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត | ៤-៥ |
| III- | កិច្ចប្រជុំស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែឧសភា ឆ្នាំ២០១៧ | ៦-១៣ |
| IV- | សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ឃឹម ណុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមិថុនា ឆ្នាំ២០១៧ | ១៤-១៥ |

# ១- សេចក្តីព្រាងអនុក្រឹត្យស្តីពី

## ឯកសណ្ឋាន សញ្ញាសម្គាល់ និងបណ្ណសម្គាល់ខ្លួន របស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត

កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឌី សុណាត** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **សុភ ផេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ **សេចក្តីព្រាងអនុក្រឹត្យ ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត** ដោយមានការអញ្ជើញចូលរួមពី សមាជិក និងមន្ត្រីនៃ គ.ស.វ. សមាជិក និងមន្ត្រីនៃ ក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល មន្ត្រីជំនាញ ទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត ដោយមានគោលបំណងពង្រឹងការងារ គ្រប់គ្រងវិស័យភាពយន្តនៅកម្ពុជា។ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានរៀបចំតាក់តែងកែសម្រួលអនុក្រឹត្យស្តីពីការគ្រប់គ្រងត្រួតពិនិត្យសិល្បៈ ភាពយន្ត វីដេអូ ទៅជាអនុក្រឹត្យស្តីពីការគ្រប់គ្រងឧស្សាហកម្មភាពយន្តវិញ ដើម្បីឆ្លើយតបទៅនឹងការវិវត្តន៍រីកចម្រើនរបស់សង្គមជាតិ និងបច្ចេកវិទ្យា ដែលអនុក្រឹត្យនេះត្រូវបាន **សម្តេចតេជោនាយករដ្ឋមន្ត្រី** ចុះហត្ថលេខាដាក់ឲ្យប្រើប្រាស់កាលពីថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦ កន្លងទៅ។ នៅក្នុងខ្លឹមសារនៃអនុក្រឹត្យនោះ ត្រង់ជំពូកទី៥ មាត្រា១៥ បានចង្អុលបង្ហាញឲ្យមន្ត្រីដែលមានភារកិច្ចត្រួតពិនិត្យឧស្សាហកម្មភាពយន្តត្រូវស្លៀកពាក់ឯកសណ្ឋានសញ្ញាសម្គាល់ និងមានបណ្ណសម្គាល់ខ្លួនក្នុងពេលបំពេញភារកិច្ចនិងបេសកកម្មដែលក្រសួងប្រគល់ជូន។

ដោយពិនិត្យឃើញនូវភាពចាំបាច់ក្នុងការពង្រឹងការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងឧស្សាហកម្មភាពយន្តឲ្យមានប្រសិទ្ធិភាព និងដើម្បីរួមចំណែកអនុវត្តច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល សំដៅធានាបាននូវការប្រកបអាជីវកម្មស្នាដៃភាពយន្ត ដោយស្មើភាព ក្នុងន័យពង្រឹងនិរន្តរភាព និងវឌ្ឍនភាព វប្បធម៌ជាតិ លើកកម្ពស់សីលធម៌ គុណធម៌ អត្តសញ្ញាណ និងកិត្យានុភាពជាតិ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានរៀបចំសេចក្តីព្រាងអនុក្រឹត្យនេះឡើង[១]។

អង្គប្រជុំបានពិនិត្យពិភាក្សាលើសេចក្តីព្រាងនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ មុននឹងដាក់ឆ្លងកិច្ចប្រជុំអន្តរក្រសួងនាពេលខាងមុខ៕

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងអនុក្រឹត្យ ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត។

# ២- សេចក្តីព្រាងអនុក្រឹត្យស្តីពី

## ការបង្កើតវិទ្យាស្ថានជាតិអប់រំពិសេស

កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេសក្រោមអធិបតីភាព ឯកឧត្តម **អ៊ីវ ថុង** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) និងឯកឧត្តម **ឃុន សុផល** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ **សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបង្កើតវិទ្យាស្ថានជាតិអប់រំពិសេស** ដោយមានការអញ្ជើញចូលរួមពី សមាជិក និងមន្ត្រីនៃ ក.ស.វ. សមាជិក និងមន្ត្រីនៃ ក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងអប់រំ យុវជន និងកីឡា។



យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា៤៨ មាត្រា៦៥ មាត្រា៦៦ បានកំណត់អំពីសិទ្ធិនៃការទទួលបានការអប់រំ លើសពីនេះទៀត មាត្រា៦៧ ក្នុងវាក្យខណ្ឌទី១ បានតម្រូវឲ្យរដ្ឋអនុវត្តកម្មវិធីសិក្សា និងគោលការណ៍គរុកោសល្យទំនើប រាប់បញ្ចូលបច្ចេកវិទ្យា និងភាសាបរទេស។ ជាពិសេសត្រង់មាត្រា៦៨ វាក្យខណ្ឌទី១ និងវាក្យខណ្ឌទី២ បានតម្រូវឲ្យរដ្ឋផ្តល់កិច្ចការអប់រំផ្នែកបឋម និងមធ្យមសិក្សានៅសាលារៀនសាធារណៈ សម្រាប់ប្រជាពលរដ្ឋគ្រប់រូបដោយឥតបង់ថ្លៃ។ ប្រជាពលរដ្ឋត្រូវបានទទួលការអប់រំយ៉ាងតិច ៩ឆ្នាំ។

ម្យ៉ាងទៀតសេចក្តីព្រាងប្រកាសទីក្រុងអ៊ីនឆុង(Incheon) និងក្របខណ្ឌសម្រាប់សកម្មភាពឆ្ពោះទៅរកការអប់រំមានគុណភាព បរិយាបន្ន សមធម៌ និងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នាបានកំណត់ចក្ខុវិស័យការអប់រំឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ដោយផ្តោតលើការអប់រំបែបបរិយាបន្ន សមភាព សំដៅលើការផ្តល់ឲ្យមនុស្សគ្រប់រូបនូវឱកាសស្មើគ្នា និងគ្មាននរណាម្នាក់ត្រូវបានទុកចោលឡើយ ដោយមិនគិតពីភេទ អាយុ សម្បុរ ជាតិសាសន៍ ជនជាតិភាគតិច ភាសា សាសនា គំនិត នយោបាយ ឬបញ្ហាផ្សេងទៀតដូចជា ដើមកំណើត ឬជនពិការ អន្តោប្រវេសន៍ ជាពិសេសអ្នកនៅក្នុងស្ថានភាពដែលងាយរងគ្រោះ។

លើសពីនេះទៀតច្បាប់ស្តីពីការអប់រំត្រង់មាត្រា៣៨ ដែលតម្រូវឲ្យរដ្ឋលើកទឹកចិត្ត និងជំរុញឲ្យមានការអប់រំពិសេសសម្រាប់ជនពិការ និងច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ត្រង់មាត្រា២៩ បានតម្រូវឲ្យក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំកម្មវិធីសិក្សាសម្រាប់គ្រឹះស្ថានសិក្សានានា ដើម្បីសម្រប

សម្រួលដល់សិស្ស និស្សិតពិការ... ជាពិសេសត្រង់មាត្រា៣១ បានកំណត់ឲ្យក្រសួងអប់រំ យុវជន និងកីឡា ត្រូវមានកម្មវិធីគរុកោសល្យអំពីពិការភាពសម្រាប់បំប៉នគ្រូ និងសាស្ត្រាចារ្យគ្រប់រូបឲ្យយល់ដឹងអំពីពិការភាព និងវិធីសាស្ត្របង្រៀនសិស្ស និស្សិតពិការ[១]។

ដើម្បីឆ្លើយតបទៅនឹងរដ្ឋធម្មនុញ្ញ ចក្ខុវិស័យការអប់រំបរិយាបន្នឆ្នាំ២០៣០ គោលនយោបាយស្ដីពីការអប់រំកុមារពិការ ច្បាប់ស្ដីពីការអប់រំ និងដើម្បីឆ្លើយតបនឹងមាត្រា៣១ នៃច្បាប់ស្ដីពីកិច្ចការពារ និងលើកកម្ពស់ជនពិការ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំសេចក្ដីព្រាងអនុក្រឹត្យ ស្ដីពីការបង្កើតវិទ្យាស្ថានជាតិអប់រំពិសេស សំដៅពង្រឹងគុណភាពនៃការបណ្ដុះបណ្ដាល និងវិក្រឹតការគ្រូបង្រៀនអប់រំពិសេស ដើម្បីលើកកម្ពស់សិទ្ធិជនពិការ ដោយអភិវឌ្ឍសមត្ថភាព សីលធម៌ បំណិន ជំនាញសមស្របក្នុងការបណ្ដុះបណ្ដាលជនពិការ ឲ្យក្លាយជាមនុស្សមានសមត្ថភាព ជំនាញស្របតាមតម្រូវការទីផ្សារការងារបច្ចុប្បន្ន។

អង្គប្រជុំបានពិនិត្យពិភាក្សាលើសេចក្ដីព្រាងនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្ដីព្រាងនេះកាន់តែល្អ មុននឹងដាក់ឆ្លងកិច្ចប្រជុំអន្តរក្រសួងនាពេលខាងមុខ៕



[១] អត្ថបទនេះដកស្រង់ពីកំណត់មូលហេតុសង្ខេបនៃសេចក្ដីព្រាងអនុក្រឹត្យ ស្ដីពីការបង្កើតវិទ្យាស្ថានជាតិអប់រំពិសេស។

# ប្រជុំបូកសរុបប្រចាំត្រីមាសទី២ ឆ្នាំ២០១៧ ស្តីពីការអនុវត្តកម្មវិធីវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត

## (Regulatory Impact Assessment Implementation)



នៅព្រឹកថ្ងៃសុក្រ ទី៣០ ខែមិថុនា ឆ្នាំ២០១៧ នៅទីស្តីការគណៈរដ្ឋមន្ត្រី ឯកឧត្តម **ឃឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងជាប្រធានក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត បានដឹកនាំប្រជុំបូកសរុបការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (RIA) ប្រចាំត្រីមាសទី២ ឆ្នាំ២០១៧ ដើម្បីពិនិត្យវាយតម្លៃលើការងារអនុវត្តកន្លងមក និងលើកផែនការសកម្មភាពសម្រាប់បន្តក្នុងឆ្នាំ២០១៧ និងទិសទៅឆ្នាំ២០១៨។

អ្នកចូលរួមមានចំនួនប្រមាណ៩០រូប ក្នុងនោះមានក្រុមRET និងក្រុមRIA មកពីក្រសួង ស្ថាប័នចំនួន ១៨៖ ក្រសួងពាណិជ្ជកម្ម ក្រសួងរ៉ែនិងថាមពល ក្រសួងបរិស្ថាន ក្រសួងទេសចរណ៍ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងកសិកម្មរុក្ខាប្រម៉ាញ់និងនេសាទ ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងសុខាភិបាល ក្រសួងប្រៃសណីយនិងទូរគមនាគមន៍ ក្រសួងសាធារណៈការ និងដឹកជញ្ជូន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ក្រសួងយុត្តិធម៌ ក្រសួងការពារជាតិ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ។

ការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត(RIA) គឺជាទម្លាប់អនុវត្តល្អសម្រាប់ដំណើរការរៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្ត ដែលផ្តល់ផលចំណេញច្រើន ហើយមានប្រទេសអភិវឌ្ឍជាច្រើនដែលជាសមាជិកនៃ OECD (អង្គការអភិវឌ្ឍសេដ្ឋកិច្ចនិងសហប្រតិបត្តិការ) និងប្រទេសASEAN បានទទួលស្គាល់យ៉ាងទូលំទូលាយថា៖

-លិខិតបទដ្ឋានមានគុណភាពខ្ពស់ ដែលមានអភិបាលកិច្ចល្អ និង ការអភិវឌ្ឍសេដ្ឋកិច្ច

-អ្នកធ្វើសេចក្តីសម្រេចអាចធ្វើការសម្រេចបញ្ញត្តិកម្មប្រកបទៅដោយទិន្នន័យផ្អែកលើការអនុវត្តជាក់ស្តែង

-បង្កើនតម្លាភាព និងកសាងជំនឿទុកចិត្តដល់សាធារណៈជន ដោយសារមានគោលការណ៍ណែនាំច្បាស់លាស់សម្រាប់កិច្ចពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ

-ជួយកាត់បន្ថយបន្ទុកចំណាយរបស់រាជរដ្ឋាភិបាលលើការអនុវត្ត និងបន្ទុកចំណាយប្រតិបត្តិការរបស់ធុរកិច្ច

អភិបាលកិច្ចល្អ គឺជាចំណុចកណ្តាលនៃរបៀបវារៈរបស់រាជរដ្ឋាភិបាលដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណ។ ដំណើរការ RIA នឹងកាត់បន្ថយការិយាធិបតេយ្យ និងភាពច្រហូស/ភាពជាន់គ្នានៃលិខិតបទដ្ឋានគតិយុត្ត៕





របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា **ប្រចាំខែឧសភា ឆ្នាំ២០១៧** នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧ ក្រោមអធិបតីភាព ឯកឧត្តម ទេសរដ្ឋមន្ត្រី **យឹម ណុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពី អនុប្រធាន សមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែឧសភា ឆ្នាំ២០១៧សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ថយចុះ0,២%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង២,៥%ធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។

តារាង១.១. បម្រែបម្រួលថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| *ក្រុមទំនិញ:* | | *មុខទំនិញ:* | |
|---|---|---|---|
| ភោជនីយដ្ឋាន: | +៦,៦% | ប្រេងសាំង: | +៩,៥% |
| ការដឹកជញ្ជូន: | +៤% | ប្រេងម៉ាស៊ូត: | +៩% |
| ម្ហូបអាហារ: | +២,៩% | ត្រីស្រស់: | +៥,៦% |
| សំលៀកបំពាក់ និងស្បែកជើង: | +២,៩% | បន្លែ: | +៣,៤% |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់: | +១,៧% | សាច់គោ: | +៣,៣% |
| គ្រឿងសង្ហារឹមនិងសម្ភារៈប្រើប្រាស់: | +១,៧% | សាច់ជ្រូក: | +២,២% |
| ការកំសាន្ត និងវប្បធម៌: | +១,៦% | សាច់មាន់: | +១,២% |
| សុខាភិបាល: | +១,២% | | |

តារាង១.២. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១៥–២០១៧

| ឆ្នាំ | ធៀបនឹងខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា[P] | កក្កដា[P] | សីហា[P] | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៧ | ដូចគ្នាឆ្នាំមុន | ៤,៤% | ៤,0% | ៤,២% | ៣,២% | ២,៥% | ២,៩% | ២,៩% | ២,៨% | | | | | |
| | មុន | 0,៣% | 0,១% | 0,0% | 0,៤% | -0,២% | 0,៧% | 0,៣% | 0,១% | | | | | |
| ២០១៦ | ដូចគ្នាឆ្នាំមុន | ៣% | ២,៣% | ២,0% | ២,៨% | ៣,១% | ៣,៣% | ៣,0% | ២,៩% | ៣,0% | ៣,៤% | ៣,៦% | ៣,៩% | ៣% |
| | មុន | -0,២% | 0,៤% | -0,២% | ១,៤% | 0,៥% | 0,២% | 0,៣% | 0,២% | 0,៣% | 0,៤% | 0 | 0,៤% | |
| ២០១៥ | ដូចគ្នាឆ្នាំមុន | 0,៤% | ១,៦% | ១,១% | ១,៣% | ១,0% | 0,៧% | 0,៨% | 0,៨% | 0,៩% | ១,៣% | ១,៩% | ២,៨% | ១,២% |
| | មុន | -0,៤% | ១,២% | 0,១% | 0,៧% | 0,១% | 0,២% | 0,៦% | 0,៣% | 0,២% | 0% | -0,២% | 0,២% | |

**P:** តួលេខខែ មិថុនា កក្កដា និងសីហាឆ្នាំ២០១៧ ជាតួលេខព្យាករ (តាមវិធីសាស្ត្រ **DECOMPOSITION)**

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ )Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

ក្រាហ្វ ១១.. ចលនានិងបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់







តារាង១.៣. អត្រាប្តូរប្រាក់

| *ប្រភេទ* | ឧសភា ២០១៧ | មេសា ២០១៧ | ឧសភា ២០១៦ | *ប្រភេទ* | ឧសភា ២០១៧ | មេសា ២០១៧ | ឧសភា ២០១៦ |
|---|---|---|---|---|---|---|---|
| **៛/ដុល្លារ** | ៤០៦៩៛/១$ | ៤០៣៤៛/១$ | ៤០៨៥៛/១$ | **បាត/ដុល្លារ** | ៣៤,១២បាត/១$ | ៣៤,៥៩បាត/១$ | ៣៥,៧២បាត/១$ |
| **៛/បាត** | ១១៩៛/១បាត | ១១៧៛/១បាត | ១១៤៛/១បាត | **ដុង/ដុល្លារ** | ២២៧១០ដុង១$ | ២២៧៣០ដុង១$ | ២២៤១៥ដុង/១$ |
| **៛/ដុង** | 0,១៧៩៛/១ដុង | 0,១៧៧៛/១ដុង | 0,១៨២៛/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងខែឧសភា ឆ្នាំ ២០១៧ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម:

**២.១. ចំណូលថវិកាជាតិ** : អនុវត្តបាន១៤៦៨,៩ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ៣៦៧,២លានដុល្លារ (*មធ្យមប្រចាំខែ១១%  នៃផែនការ*) ក្នុងនោះចំណូលចរន្តចំនួន១៣៦៣,៧ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ៣៤០,៩លានដុល្លារ (*មធ្យមប្រចាំខែ ១១០% នៃផែនការ*) និងចំណូលមូលធនមានចំនួន១០៥,២ ប៊ីលានរៀល (*មធ្យមប្រចាំខែ ៣៩១% នៃផែនការ*) (តាមតួលេខ រតនាគារជាតិ)។

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១៥–២០១៧ (ប៊ីលានរៀល)




➢បើធៀបនឹងខែមុន ចំណូលថវិកាជាតិថយចុះ១១,២% ប៉ុន្តែ កើនឡើង៧,៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢នៅក្នុងចំណូលចរន្ត:

✓ចំណូលសារពើពន្ធមានចំនួន ១១៨៣,១ប៊ីលានរៀល ថយចុះ១៣,៩% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៧,៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន (តាមតួលេខ រតនាគារជាតិ)។

✓ចំណូលមិនមែនសារពើពន្ធ មានចំនួន១៨០,៥ប៊ីលានរៀល កើនឡើង៤៤,៨% ធៀបនឹងខែមុន ប៉ុន្តែថយចុះ ២៩,៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន(តាមតួលេខ រតនាគារជាតិ)។

| តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ | | | |
|---|---|---|---|
| **ចំណូលសារពើពន្ធ** (ក្នុងរង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | **ចំណូលមិនមែនសារពើពន្ធ** (តាមតួលេខ រតនាគារជាតិ) (ក្នុងរង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
| ➢ ពន្ធ និងអាករគយ: +៣% (អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) | (+១០,៨%) | ➢កាស៊ីណូ : +៥៧,៥% | (+១៥,៦%) |
| ➢ ចំណូលពន្ធដារ: -៣៦,៤% (អគ្គនាយកដ្ឋានពន្ធដារ) | (+១៣,៦%) | ➢អាជ្ញាបណ្ណក្នុងស្រុក : -៣៥,៧% | (-៨៣%) |
| | | ➢ នេសាទ: +៣៥៩,៧% | (+៩៥%) |
| | | ➢សម្បទានរ៉ែ: -៣៣,៩% | (-៥៧,៩%) |
| | | ➢ អាកាសចរណ៍ស៊ីវិល: +៧០៦,៧% | (+១០៥,៣%) |
| | | ➢ផលទុននៃសកម្មភាពទេសចរណ៍: -៨% | (-៤៤,២%) |
| | | ➢អាករស្នានទូត(លិខិតឆ្លងដែននិងទិដ្ឋាការ): -៤៤,៦% | (-៥២,៤%) |
| | | | (-៨៧,៥%) |
| | | ➢ការត្រួតពិនិត្យគុណភាពផលិតផល: +២៦៦,៥% | |

**២.២. ចំណាយថវិកាជាតិ** : អនុវត្តបាន ១០៣២,៧ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ២៥៨,១៨លានដុល្លារ (*មធ្យមប្រចាំខែ ៦៥% នៃផែនការ*) ក្នុងនោះ ចំណាយចរន្តចំនួន ៩៣១,១ប៊ីលានរៀល (*មធ្យមប្រចាំខែ ៧០% នៃផែនការ*) និងចំណាយមូលធនមានចំនួន ១០១,៦ប៊ីលានរៀល(តាមតួលេខ រតនាគារជាតិ)។

➢ចំណាយថវិកាជាតិកើនឡើង៣៨,២% ធៀបនឹងខែមុននិងកើនឡើង១១,៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្តកើនឡើង៤៦,៥% ធៀបនឹងខែមុននិងកើនឡើង១៤,៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

**២.៣. សមតុល្យថវិកាជាតិ**: ថវិកាជាតិនាខែនេះមានអតិរេកចំនួន ៤៣៦,២ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ១០៩លានដុល្លារ (តួលេខរតនាគារជាតិ)។

ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១៥–២០១៧ (ប៊ីលានរៀល)




## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែឧសភា ឆ្នាំ២០១៧មានលក្ខណៈដូចខាងក្រោម:

➢រូបិយវត្ថុ$M_2$ មានចំនួន ៦២៩២១ប៊ីលានរៀល កើនឡើង១,៩%ធៀបនឹងខែមុន និងកើនឡើង១៧,៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ **ការកើនឡើង** **$M_2$** ក្នុងខែនេះ ជារួម បណ្ដាលមកពីការកើនឡើងនៃរូបិយវត្ថុក្រៅធនាគារ១,៣% ប្រាក់បញ្ញើចរន្ត ២៦,៧% ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ ៨,៣% និងប្រាក់បញ្ញើជារូបិយបណ្ណ១,៥%។

ក្រាហ្វ៣.១. សមាសធាតុរូបិយវត្ថុខែមេសា ឆ្នាំ២០១៧



➢ក្នុងខែនេះ ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារមានចំនួន១៥,៧% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន ៨៤,៣% នៃរូបិយវត្ថុ$M_2$។

តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ $M_2$ ឆ្នាំ២០១៧

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | ១៦,៧% | ១៦,៦% | ១៥,៤% | ១៥,៣% | ១៥,៧% | | | | | | | |
| ប្រាក់រៀលក្រៅធនាគារ | ១១,៣% | ១១,៤% | ១១,៣% | ១១,៣% | ១១,២% | | | | | | | |

ក្រាហ្វ៣.២.បម្រែបម្រួលសមាសធាតុរូបិយវត្ថុខែឧសភា២០១៧: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន




➢**ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ** មានចំនួន៧៥៦៦លានដុល្លារ កើនឡើង២,៦%ធៀបនឹងខែមុន និងកើនឡើង៣៦,៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** : ក្នុងខែនេះមានចំនួន ២២៩៣២ប៊ីលានរៀលកើនឡើង ៧,៦%ធៀបនឹងខែមុន និងកើនឡើង៣៣,៦%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៣.២.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំឆ្នាំ

| *ផ្តល់ដោយ* | *ឧសភា២០១៧* | *មេសា២០១៧* | *ឧសភា២០១៦* |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ(ប៊ីលានរៀល)<br>ក្នុងនោះ ជារៀល | ៦០៧០៣ | ៥៩៦៦៤ | ៥៤៤៩៥<br>៧៩៤ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ប៊ីលានរៀល) | | ១៣៨៣៦ | ១១២៦៤ |
| អត្រាការប្រាក់បញ្ញើជារៀលនៅធនាគារពាណិជ្ជ | | ៦,០២% | ៦,៧៦% |
| អត្រាការប្រាក់កម្ចីជារៀលនៅធនាគារពាណិជ្ជ | | ១៤,៨៤% | ១៦,២៦% |
| អត្រាការប្រាក់បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | | ៤,៤០% | ៤,៥១% |
| អត្រាការប្រាក់កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | | ១១,៦៤% | ១១,៧១% |
| អត្រាការប្រាក់កម្ចីជារៀលនៅហត្ថាកសិករ | | ១៥% | ៣១,២% |
| អត្រាការប្រាក់កម្ចីជារៀលនៅអម្រឹត | | ២៧% | ២៨,៨% |
| អត្រាការប្រាក់កម្ចីជារៀលនៅប្រាសាក់ | | ២២,៨% | ២២,៨% |

## ៤)ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងទេសចរណ៍

➡ក្នុងខែឧសភាឆ្នាំ២០១៧ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម:

➢**កសិកម្ម**:

✓នេសាទសម្រេចបាន៤៩,៨ពាន់តោន កើនឡើង៥%ធៀបនឹងខែមុន និងកើនឡើង៥%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➤**រ៉ែ និងថាមពល:**

✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន៦៤៧,៨៦GWHមានការកើនឡើង០,៣%ធៀបនឹងខែមុន និងកើនឡើង៨%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន២៩៥,២៨GWH មានការកើនឡើង២២%ធៀបនឹងខែមុន និងកើនឡើង៣៤១%ធៀបនឹងខែដូចគ្នាឆ្នាំមុន អគ្គីសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន២៧៥,០៥GWHមានការថយចុះ១០% ធៀបនឹងខែមុន ប៉ុន្តែមានការកើនឡើង៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➤**ឧស្សាហកម្ម:**

✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន៥៧៩,១លានដុល្លារមានការកើនឡើង១៨% ធៀបនឹងខែមុន និងកើនឡើង១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៤.១. ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| *ប្រភេទ* | *ចំនួន —ឧសភា២០១៧* | *ចំនួន—មេសា២០១៧* | *ចំនួន—ឧសភា២០១៦* |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ៥ | ១៦ | ១០ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១៦១២ | ១៦០៧ | ១៥១១ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ១៤ | ២១ | ១១ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ២១ | ១៨ | ១២ |

➤**សំណង់** (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ៦៦៥,៩ពាន់ម²ថយចុះ៨១%ធៀបនឹងខែមុន និងថយចុះ៥៧% ធៀបនឹងខែ ដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង៣៣៨៩,៩លានដុល្លារកើនឡើង២៤%ធៀបនឹងខែមុន និងកើនឡើង៣០៧%បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន:

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| *ប្រភេទ* | *ពាន់ម²—ឧសភា២០១៧* | *ពាន់ម²—មេសា២០១៧* | *ពាន់ម²—ឧសភា២០១៦* |
|---|---|---|---|
| ▪ លំនៅឋាន | ៤៥៥,១ | ១៣១៧,៣ | ៧៧៥ |
| ▪ ឧស្សាហកម្ម | ២២,៥ | ៣៣,៨ | ១៩២,៩ |
| ▪ពាណិជ្ជកម្ម | ១៤៤,៥ | ២១៤១,២ | ៤៣៨ |
| ▪ ទេសចរណ៍ | ៤១,៦ | ៣៨,៤ | ១២២,៦ |
| ▪ផ្សេងៗ | ០,៤ | ០,៧ | ០,០ |
| អនុញ្ញាតសរុប | ៦៦៥,៩ | ៣៥៣២ | ១៥៣២,៥ |

✓ដូច្នេះ សំណង់អនុញ្ញាតដែលពេញនិយមនាខែនេះ គឺលំនៅដ្ឋាន៦៨,៣% និងពាណិជ្ជកម្ម២១,៧% នៃផ្ទៃក្រឡាសរុប។

តារាង៤.៣. ការស្វែងរកការងារនិងទទួលបានការងារ

| *ប្រភេទ* | *នាក់—ឧសភា ២០១៧* | *នាក់—មេសា ២០១៧* | *នាក់—ឧសភា ២០១៦* |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ( ទីភ្នាក់ងារជាតិមុខរបបនិងការងារ) | ៧៥១ | ១៣១០ | ១៥៩៧ |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ១៣៣៧៥ | ១១៩៣៣ | ៩៥៧៤ |
| អ្នកទទួលបានការងារក្នុងប្រទេស | ៩៦៧៦ | ៨៧៣៧ | ៦៣០២ |
| អ្នកទទួលបានការងារក្រៅប្រទេស | ៣៦៩៩ | ៣១៩៦ | ៣២៧២ |

## ➢វិនិយោគ

តារាង៤.៤.គម្រោងវិនិយោគអនុញ្ញាតដោយគ.វ.ក./ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | ឧសភា២០១៧ | មេសា២០១៧ | ឧសភា២០១៦ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ១០០៨ | ៨៧ | ២៣,៧ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ០ | ០ | ០ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ៣២ (៣) | ៨៧ (៥៨) | ២១,១ (១៤,២) |
| វិស័យទេសចរណ៍ | ០ | ០ | ២,៦ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ៩៧៦ | ០ | ០ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ៨ | ១០ | ២ |
| បង្កើតការងារ (ពាន់នាក់) | ៧ | ១៤ | ៥ |

➢**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប៥កំពង់ផែ) មានចំនួន ៨៣៩,៤ពាន់តោនថយចុះ១៤%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៩%ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ:

តារាង៤.៥.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន)

| | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ:+២% | (+១៩%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង:+១៩៧% | (-១០%) |
| ▪ កំពង់ផែកំពង់សោម:-១១% | (+២០%) | ▪ កំពង់ផែឧកញ៉ាម៉ុង: -១០០% | (-១០០%) |

## ➢ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ចំនួន | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ១៨,៦ | +២៦% | +៣៦% |
| ក្នុងនោះទទួល | ២,៥ | +២៨% | +២២% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ៩៦,៤ | +៥% | +១៧% |
| ក្នុងនោះទទួល | ៦១ | +៣១% | +៣៣% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ២៤១៨,១ | +៨% | -១៣% |
| ក្នុងនោះហៅចូល | ៧០១,១ | +៣% | -១៧% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ១០៤២៣,៦ | +២១% | +១៦% |
| ក្នុងនោះហៅចូល | ១០៣៦២,១ | +២២% | +១៦% |

## ➢ ការធ្វើដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

តារាង៤.៧.អ្នកដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

| ប្រភេទ | ចំនួន(ពាន់នាក់) | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១២,៥ | -៣០% | ២% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ៣៧,១ | -១៩% | ៤២% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៥២៤,២ | -៩% | ២៩% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ១៥៤,៨ | -១២,៥% | ២២% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ៣៦៨,៨ | -១១% | ១៥% |
| ✓ តាមផ្លូវអាកាស | ២១៧,៤ | -១១% | ៣១% |
| ✓ តាមផ្លូវគោក និងទឹក | ១៥១,៥ | -១០% | -២% |

## ៥) ស្ថានភាពជញ្ជូនពាណិជ្ជកម្ម

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនា ខែឧសភាឆ្នាំ២០១៧ មានចំនួន៤៨៤៥,៨ប៊ីលានរៀល (ស្មើនឹង១២១១,៥លានដុល្លារ ស.រ.អា.) កើនឡើង៩,២%ធៀបនឹងខែមុន និងកើនឡើង៨,៧% ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ :

តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | -៤,៦% | +១១,៦% | រថយន្តសរុប (ប៊ី.ល.រ) | -២,៣% | +១៣% |
| ប្រេងម៉ាស៊ូត | +៣,៩% | +១៨% | រថយន្តសរុប (គ្រឿង) | +១០,៣% | -៤% |
| ឧស្ម័ន | -១៤,១% | +១៨,៤% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | +៤,៩% | +២២,៥% |
| អគ្គិសនីនាំចូល | -២៥% | -៦៨% | ម៉ូតូ (គ្រឿង) | +១៥,៦% | +២៥,១% |
| ដែកសំណង់ | +១០% | -២៧,៤% | អង្ករ | -៧៦,៥% | -៨៧,៧% |
| ស៊ីម៉ង់ត៍ | +១៦,៥% | -១៤,៦% | ផ្លែឈើនិងបន្លែ | +៥០,១% | -៥,៣% |
| គ្រឿងអេឡិចត្រូនិក | -៦,៥% | +១២,៦% | ជីនិងថ្នាំកសិកម្ម | +៤៦,៩% | +៥១,៦% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | +១៧,៨% | +៨,៦% |

➡ **ការនាំចេញ** ខែឧសភា ឆ្នាំ២០១៧ មានចំនួន**៣៣០៩,២**ប៊ីលានរៀល ស្មើនឹង៨២៧,៣លានដុល្លារ ស.រ.អា. (**៦៨,៣**% នៃការនាំចូល)កើនឡើង៣,៦%ធៀបនឹងខែមុន និងកើនឡើង៩%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៥.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | +៣១,៩% | +៩៧,៧% | ផលិតផលនេសាទ | +៨៦,២% | +៥០៩,៧% |
| វាយនភណ្ឌនិងស្បែកជើង | +១៨,៧% | +៣,៩% | កៅស៊ូ | +១១៦,៥% | +៧៦,២% |
| អង្ករ | -១,៥% | +២១,៤% | | | |

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែឧសភា ឆ្នាំ២០១៧នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចក្នុងតារាងខាងក្រោម។

តារាង៦.១. បម្រែមប្រួលគួរឲ្យចាប់អារម្មណ៍ នៃសូចនាករមួយចំនួន

| ល.រ | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ចំណូលពីអាជ្ញាបណ្ណក្នុងស្រុក | -35.7% | -83.0% | |
| ២ | ការនាំចូលបារី | -89.4% | -87.4% | — |
| ៣ | | | | — |



## ៧) សេចក្តីសន្និដ្ឋាន

វិស័យកសិកម្ម ទាំងដំណាំ ទាំងការចិញ្ចឹមសត្វ កំពុងស្ថិតក្នុងស្ថានភាពមិនអំណោយផល ដោយមានការធ្លាក់ចុះនូវការផលិតនិងការនាំចេញ ឯកសិករប្រឈមនឹងការចុះថោកនៃផលិតផលកសិកម្ម ការប្រកួតប្រជែងតឹងតែងជាមួយការនាំចូលពីប្រទេសជិតខាង ការធ្លាក់ចុះយ៉ាងគំហុកនៃប្រាក់ចំណូលនិងការក្ស័យធន។ កសិផលសំខាន់ៗមាន ស្រូវ កៅស៊ូ ពោត បន្លែស្វាយចន្ទី និងដំឡូងមី មួយចំនួនត្រូវបាននាំចេញទៅប្រទេសជិតខាងដោយមិនទាន់កែច្នៃ ប៉ុន្តែបច្ចុប្បន្នប្រទេសជិតខាងឈប់ឬកាត់បន្ថយការទិញកសិផលកម្ពុជា ដូច្នេះកង្វះទីផ្សារជាបញ្ហាធ្ងន់ធ្ងរសម្រាប់កសិករកម្ពុជា។

ដើម្បីអភិវឌ្ឍវិស័យកសិកម្ម ចាំបាច់តម្រូវឲ្យមានកំណែទម្រង់គោលនយោបាយ ជំរុញការវិនិយោគ និងពេលវេលា ដើម្បីកសាងមូលដ្ឋានផលិតកម្មដ៏រឹងមាំមួយ ឧទាហរណ៍ បង្កើតឧស្សាហកម្មកែច្នៃផលិតផលកសិកម្ម ពង្រីកទីផ្សារកសិផល ប្រព័ន្ធធារាសាស្ត្រ បង្កើតគ្រាប់ពូជល្អ ផលិតកម្មជីកសិកម្ម និងបង្កើនការគាំទ្រផ្នែកបច្ចេកទេសដូចប្រទេសជិតខាងដែលបានអនុវត្តយូរហើយ៕

## IV- សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី យឹម ណុលឡា ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមិថុនា ឆ្នាំ២០១៧

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/០៦/១៧<br>ម៉ោង០៨:០០នាទី | ចូលរួមកិច្ចប្រជុំតាមដាន និងត្រួតពិនិត្យការរៀបចំយុទ្ធនាការឃោសនាបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ អាណត្តិទី៤ ឆ្នាំ២០១៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ចិន ឈិន** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តតាកែវ នៅមន្ទីរគណៈកម្មាធិការគណបក្សខេត្តតាកែវ។ |
| ២ | ០៥/០៦/១៧<br>ម៉ោង១១:០០នាទី | ជួបពិភាក្សាការងារជាមួយឯកឧត្តម **ផែន សុទិដ្ឋារ៉ោ** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ០៦/០៦/១៧<br>ម៉ោង០៨:៣០នាទី | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមេសា ឆ្នាំ២០១៧ នៅទីស្តីការ គណៈរដ្ឋមន្ត្រី។ |
| ៤ | ០៨/០៦/១៧<br>ម៉ោង០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីមីទ្ទិញអបអរសាទរខួបលើកទី៦៨ ទិវាកុមារអន្តរជាតិ ១មិថុនា ខួបលើកទី១៦ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា និងទិវា កុមារកម្ពុជាឆ្នាំ២០១៧ ក្រោមប្រធានបទ "លើកកម្ពស់ការចូលរួមរបស់កុមារដើម្បីអភិវឌ្ឍន៍សង្គម" និង "ការពារកុមារពីពលកម្មកុមារនៅក្នុងស្ថានភាពជម្លោះ និងគ្រោះមហន្តរាយ" ក្រោមអធិបតីភាព លោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានកិត្តិយសក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ នៅសាលមហោស្រពនៃមណ្ឌលសន្និបាត និងពិព័ណ៌កោះពេជ្រ។ |
| ៥ | ០៩/០៦/១៧<br>ម៉ោង០៩:៣០នាទី | ដឹកនាំកិច្ចប្រជុំក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានឃុំ ០៦ នៃស្រុកព្រៃកប្បាស ខេត្តតាកែវ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៦ | ១០/០៦/១៧<br>ម៉ោង០៨:០០នាទី | ចូលរួមប្រជុំបូកសរុបលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ អាណត្តិទី៤ ឆ្នាំ២០១៧ របស់ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ចិន ឈិន** សមាជិកគណៈអចិន្ត្រៃយ៍ នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តតាកែវ នៅមន្ទីរគណៈកម្មាធិការគណបក្សខេត្តតាកែវ។ |
| ៧ | ១៣/០៦/១៧<br>ម៉ោង០៩:០០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ ២០១៧-២០២៥។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់។<br>៣-បញ្ហាផ្សេងៗ។ ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៨ | ១៥/០៦/១៧<br>ម៉ោង០៩:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីជួបសំណេះសំណាល និងផ្តល់ប្រាក់រង្វាន់ជ័យលាភីជូន កីឡាការិនីដែលទទួលបានមេដាយប្រាក់០១គ្រឿង គ្រូបង្វឹក និងគ្រូជំនួយ ដែលបានចូលរួមហ្វឹកហាត់ និងត្រឡប់មកពីការប្រកួតកីឡាដូរងារ ជើងឯកពិភពលោកក្នុង ខែមករា ឆ្នាំ២០១៧ នៅសាធារណរដ្ឋកូរ៉េ ក្រោមអធិបតីភាព ឯកឧត្តម **ចិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៩ | **១៥/០៦/១៧ ម៉ោង១៦:០០នាទី** | ចូលរួមជាកិត្តិយសក្នុងពិធីពិសាអាហារស្រាយបួសខែរ៉ាម៉ាឧនឆ្នាំ២០១៧ នៃសាសនាឥស្លាម កម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅមជ្ឈមណ្ឌលពិព័រណ៍កោះពេជ្រ។ |
| ១០ | **១៦/០៦/១៧ ម៉ោង០៨:៣០នាទី** | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀប វារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ ២០១៧-២០២៥។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការ ត្រួតពិនិត្យផលិតផលថ្នាំជក់។<br>៣-បញ្ហាផ្សេងៗ៖សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័នពីស្ថានប័ននីតិប្បញ្ញត្តិលើ "កិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់សុពលភាព នៃប្រកាសនីយបត្រគក្កកម្មអឺរ៉ុប រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងអង្គភាពប្រកាសនីយបត្រគក្កកម្មអឺរ៉ុប"។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១១ | **២៥/០៦/១៧ ម៉ោង០៨:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៦៦ ថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា។ |
| ១២ | **២៦/០៦/១៧ ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបិទវគ្គប្រគល់វិញ្ញាបនបត្រ ជូនកម្មសិក្សាការីជាន់ខ្ពស់ និងមធ្យមឆ្នាំ២០១៦ និងសិក្ខាកាមវគ្គខ្លី នៃក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងបើកវគ្គបណ្តុះបណ្តាលឆ្នាំ២០១៧ របស់សាលាភូមិន្ទរដ្ឋបាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅវិទ្យាស្ថានជាតិអប់រំ។ |
| ១៣ | **២៧/០៦/១៧ ម៉ោង០៩:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធដាក់ឲ្យដំណើរការនូវមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ម.ត.ឯ.ច) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានី ភ្នំពេញ។ |
| ១៤ | **២៨/០៦/១៧ ម៉ោង០៨:០០នាទី** | ចូលរួមក្នុងពិធីរំលឹកខួបអនុស្សាវរីយ៍លើកទី៦៦ ថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា ២៨.០៦.១៩៥១ - ២៨.០៦.២០១៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ប៊ិន ឈិន** សមាជិកគណៈអចិន្ត្រៃយ៍ នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តតាកែវ នៅមន្ទីរគណៈកម្មាធិការគណបក្សខេត្តតាកែវ។ |
| ១៥ | **២៩/០៦/១៧ ម៉ោង០៨:៣០នាទី** | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែឧសភា ឆ្នាំ២០១៧ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | **២៩/០៦/១៧ ម៉ោង១៥:៣០នាទី** | ដឹកនាំកិច្ចប្រជុំគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ប្រចាំខែឧសភា ឆ្នាំ២០១៧ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

# ព្រឹត្តិបត្រព័ត៌មាន



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in